ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២១
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២១ សរុបមានចំនួន ៣៥ ៤២៥,៤ លានរៀល ក្នុងនោះ ៖

**(ក) រដ្ឋបាលកណ្តាល**៖ បានគ្រោងចំណូលសរុបចំនួន ៣៥ ៤២៤ លានរៀល ចំណូលនេះរួមមាន : (១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២០ ៩៩២ លានរៀល ស្មើនឹង៧៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ១១ ១៦២ លានរៀល ស្មើនឹង១០៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៣ ២៧០ លានរៀល ស្មើនឹង១១៤,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០។

**(ខ) មន្ទីររាជធានី ខេត្ត**៖ បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង ១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នៅក្នុងត្រីមាសទី៣ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូល សរុបមានចំនួន ២២ ៨៦៣,២លានរៀល ស្មើនឹង៦៤,៥%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៣៤៧,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

**(ក) រដ្ឋបាលកណ្តាល**៖ អនុវត្តប្រមូលចំណូល សរុបមានចំនួន២២ ៨៦៣,២លានរៀល ស្មើនឹង៦៤,៥ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៣៤៧,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន (១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន៦ ៣៣៥,១ លានរៀល ស្មើនឹង៣០,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង២២០,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន៣ ៩៧០,២ លានរៀល ស្មើនឹង ៣៥,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៤០,៣%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៥៨៩,៤ លានរៀល ស្មើនឹង១៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០

៦៦,៧ % ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(៤)ផលហិរញ្ញវត្ថុ មានចំនួន ៣លានរៀល ដែលជាចំណូលបានមកពីការបង់សំណោសចំណាយប្រាក់បៀវត្សនិង(៥) ផលពិសេសផ្សេងៗមានចំនួន ១១ ៩៦៥,៦លានរៀល ដែលជាចំណូលមិនបានគ្រោងនៅក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១។

**(ខ) មន្ទីររាជធានី ខេត្ត ៖**

នៅក្នុងត្រីមាសទី៣នេះ មន្ទីរមិនទាន់បានអនុវត្តចំណូលពីថ្លៃឈ្នួលដីនៅឡើយ។

ជារួមការអនុវត្តចំណូលរបស់រដ្ឋបាលកណ្តាលសម្រេចបានខ្ពស់។ ម្យ៉ាងទៀត ដោយពិនិត្យទៅតាមប្រភេទចំណូលនីមួយៗឃើញថាមានភាពកើនខ្ពស់ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ជាក់ស្តែងដូចជា៖

(១) ផលទុននៃទ្រព្យសម្បត្តិរដ្ឋអនុវត្តបាន២២០,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះដោយសារចំណូលផលពីព្រៃឈើអនុវត្តបាន៤០,៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៧៥៧,៣%ធៀបនឹងកម្មវិធីដែលបានដាក់ចេញនិងចំណូលពីសម្បទានដីសេដ្ឋកិច្ចអនុវត្តបាន២១,៤%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង១០៤,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវា អនុវត្តបានខ្ពស់គឺដោយសារចំណូលពីការលក់ឯកសារ លតាប័ត្រនិងលិខិតបោះពុម្ពផ្សេងៗអនុវត្តបាន១៩១,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១ ១៤៩,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ អនុវត្តបានចំនួន ១៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៧៤,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ចំពោះការជួលទ្រព្យសម្បត្តិរដ្ឋអនុវត្តបាន១៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៩២,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញគឺដោយសារការជួលដីទំនេរអនុវត្តបាន ២១៤,៦ធៀបនឹងកម្មវិធីដែលបានដាក់ចេញ រីឯដីមានអគារអនុវត្តបានទាបគឺ១២,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកចំណូលផលពីការគ្រប់គ្រងរដ្ឋបាលដែលបានពីការត្រួតពិនិត្យអនាម័យសត្វនិងការត្រួតពិនិត្យគុណភាពផលិតផល អនុវត្តបាន៤០,២%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៤៧,៥%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(៣) ចំណូលពីការផាកពិន័យ និងដាក់ទណ្ឌកម្មអនុវត្តបាន១៨%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង ៦៦,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ លទ្ធផលនេះបានមកដោយសារការផាកពិន័យលើផលិតផលសាច់សត្វនិងការដឹកជញ្ជូនសត្វរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ អនុវត្តបាន១៨៥ %ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង២៣១,៣%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការទិញ-លក់ជីនិងថ្នាំកសិកម្មខុសច្បាប់ អនុវត្តបាន៥,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៦,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការនេសាទខុសច្បាប់ អនុវត្តបាន១១០,៧%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៧៧,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងការពិន័យលើបទល្មើសព្រៃឈើ អនុវត្តបាន១៨,៩ %ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៤៣,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។

## III-**ទិសដៅអនុវត្តបន្ត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី៤ឆ្នាំ២០២១ ដែលមានទឹកប្រាក់សរុបចំនួន៧ ៩០០លានរៀល។ កិច្ចការបន្ទាន់មួយទៀតដែលក្រសួងត្រូវអនុវត្ត គឺបន្តរៀបចំឯកសារកែសម្រួលកម្រងសេវាសាធារណៈនិងសេចក្តីព្រាងប្រកាសអន្តរក្រសួងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

IV-**សេចក្ដីសន្និដ្ឋាន**

សរុបសេចក្តីមកការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី៣ របស់រដ្ឋបាលកណ្តាលសម្រេចបានលទ្ធផលល្អប្រសើរ គឺលើសផែនការធៀបនឹងកម្មវិធីដែលបានដាក់ចេញទាំងផ្នែកចំណូលពីសេវាសាធារណៈ និងការជួលដីធ្លី ។ ទោះបីយ៉ាងនេះក្តីការអនុវត្តចំណូលមួយចំនួននៅទាបធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ដូចជាចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល ចំណូលពីការលក់ផលិតផលកសិកម្មនិង ចំណូលពីសម្បទានដីសេដ្ឋកិច្ច។ម្យ៉ាងទៀត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺក៍មិនទាន់បានអនុវត្តប្រមូលចំណូលពីថ្លៃឈ្នួលដីទំនេរផងដែរ។

ដូច្នេះដើម្បីអនុវត្តប្រមូលចំណូលឲ្យបានតាមផែនការឆ្នាំ២០២១ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលឲ្យបានទាន់ពេលវេលា គួបផ្សំនឹងការប្រតិបត្តិតាមនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ថ្ងៃពុធ១៤កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១

**រដ្ឋលេខាធិការនិងជាអនុប្រធានក្រុមការងាររៀបចំថវិកា**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**